# ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១៧៤

## ស្តីពី
## ការបង្កើតគណៈស្ថាបត្យករកម្ពុជា

---

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈស្ថាបត្យករកម្ពុជាដែលសរសេរជាអក្សរកាត់ថា គ.ស.ក. និងដែលមានគោលបំណងប្រមូលផ្តុំនិងគ្រប់គ្រងស្ថាបត្យករដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលើកកម្ពស់វិជ្ជាជីវៈ គុណភាពស្នាដៃរបស់ស្ថាបត្យករ និងកិត្យានុភាពនៃស្ថាបត្យកម្មកម្ពុជា។

**មាត្រា ២.-**

ព្រះរាជក្រឹត្យនេះមានគោលដៅដូចតទៅៈ

- រួមចំណែករៀបចំវិជ្ជាជីវៈស្ថាបត្យកម្មឲ្យកាន់តែល្អប្រសើរ ដើម្បីការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ថាបត្យករ
- រួមចំណែកថែរក្សា ការពារ អភិវឌ្ឍស្ថាបត្យកម្មខ្មែរ និងលើកកម្ពស់អត្តសញ្ញាណជាតិ
- ពង្រឹងនិងលើកកម្ពស់សមត្ថភាពនិងគុណភាពបន្ថែមដល់ស្ថាបត្យករដែលប្រកបមុខរបរអាជីវកម្ម ដោយគោរពខ្ជាប់ខ្ជួននូវក្រមសីលធម៌
- ធានាឲ្យបានការប្រកបវិជ្ជាជីវៈស្ថាបត្យកម្មមានគុណភាព ប្រសិទ្ធភាព សុវត្ថិភាព ស្ថិរភាព និងមានការទទួលខុសត្រូវខ្ពស់ក្នុងការការពារទេសភាពធម្មជាតិនិងបេតិកភណ្ឌជាតិ
- ពង្រឹងនិងបើកទូលាយទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ព្រមទាំងធ្វើសមាហរណកម្មស្ថាបត្យកម្មជាតិចូលក្នុងពិភពលោកនិងក្នុងតំបន់ ជាពិសេសក្នុងសមាគមជាមួយបណ្តាប្រទេសអាស៊ាន
- ទទួលស្គាល់ទេពកោសល្យរបស់ស្ថាបត្យករកម្ពុជា ដើម្បីឲ្យមានគោរមងារជាស្ថាបត្យករជាតិនិងអន្តរជាតិ
- រួមចំណែកក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈស្ថាបត្យកម្ម ដើម្បីអភិវឌ្ឍធនធានមនុស្សឲ្យស្របតាមតម្រូវការសង្គមជាតិ តម្រូវការតំបន់ និងតម្រូវការពិភពលោក
- លើកទឹកចិត្តស្ថាបត្យករដែលបង្កើតទស្សនៈស្ថាបត្យកម្មថ្មីៗនិងស្ថាបត្យកម្ម ដែលមានលក្ខណៈជាអត្តសញ្ញាណជាតិគួបផ្សំនឹងលក្ខណៈទំនើប។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេស ដែលបានចុះឈ្មោះក្នុងបញ្ជី គ.ស.ក។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងព្រះរាជក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ស្ថាបត្យកម្ម** សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃការបង្កើតរចនាសម្ព័ន្ធអគារនិងការសាងសង់ទាំងក្នុងនិងក្រៅនៃសំណង់ផ្សេងៗ ស្របតាមលក្ខណៈបច្ចេកទេសនិងតាមសំណុំសោភណភាពដែលបានគ្រោងទុក ដោយឆ្លុះបញ្ចាំងពីអត្តសញ្ញាណជាតិ សង្គម និងការការពារបរិស្ថាន។
- **ស្ថាបត្យករ** សំដៅដល់រូបវន្តបុគ្គលខ្មែរនិងបរទេសដែលបានបញ្ចប់ការសិក្សាជំនាញស្ថាបត្យកម្មដោយជោគជ័យ តាមគ្រឹះស្ថានឧត្តមសិក្សានានានៅព្រះរាជាណាចក្រកម្ពុជាឬនៅបរទេស ហើយមានការទទួលស្គាល់សញ្ញាបត្រស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
- **ស្ថាបត្យករចុះបញ្ជី** សំដៅដល់ស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេសដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** ហើយមិនទាន់បានបំពេញលក្ខខណ្ឌដើម្បីក្លាយជាស្ថាបត្យករ **គ.ស.ក.**។
- **ស្ថាបត្យករគ.ស.ក.** សំដៅដល់ស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេសដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** ហើយបានបំពេញលក្ខខណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សា **គ.ស.ក.**និងស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
- **ស្ថាបត្យករអាស៊ាន** សំដៅដល់រូបវន្តបុគ្គលដែលមានសញ្ជាតិក្នុងប្រទេសជាសមាជិកអាស៊ាននិងបានបំពេញលក្ខខណ្ឌត្រឹមត្រូវស្របតាមកិច្ចព្រមព្រៀងនៃការទទួលស្គាល់គ្នាទៅវិញទៅមកលើសេវាកម្មស្ថាបត្យកម្មរបស់អាស៊ានក្រោមការត្រួតពិនិត្យនិងការវាយតម្លៃរបស់ក្រុមប្រឹក្សាស្ថាបត្យករអាស៊ាន។
- **វិជ្ជាជីវៈស្ថាបត្យកម្ម** សំដៅដល់រាល់ការងារពាក់ព័ន្ធនឹងការសិក្សា ការរៀបចំនិងការអនុវត្តគម្រោងប្លង់ស្ថាបត្យកម្ម និងលិខិតបទដ្ឋានបច្ចេកទេសទាំងឡាយដែលទាក់ទងនឹងការងារស្ថាបត្យកម្ម។

## ជំពូកទី២
## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈស្ថាបត្យករកម្ពុជា
### ផ្នែកទី១
### ប្រធានកិត្តិយសនៃគណៈស្ថាបត្យករកម្ពុជា

**មាត្រា ៥.-**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយសនៃ **គ.ស.ក.**។

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

**មាត្រា ៦.-**

ប្រធានកិត្តិយសនៃ **គ.ស.ក.** ជាអធិបតីក្នុងមហាសន្និបាត **គ.ស.ក.** និងផ្តល់អនុសាសន៍ណែនាំដល់ **គ.ស.ក.**។

ក្នុងករណីចាំបាច់ ប្រធានកិត្តយសនៃ **គ.ស.ក.**អាចប្រគល់ភារកិច្ចជូនឥស្សរជនណាមួយធ្វើជាតំណាងដើម្បីធ្វើជាអធិបតីក្នុងមហាសន្និបាត **គ.ស.ក.** ។

## ផ្នែកទី២

## ក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា

**មាត្រា ៧.-**

ក្រុមប្រឹក្សា **គ.ស.ក.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| - ឥស្សរជនជាន់ខ្ពស់នៃស្ថាប័នជាតិឬឥស្សរជនកម្ពុជា ដែលមានបទពិសោធខាងវិស័យស្ថាបត្យកម្ម | អនុប្រធាន |
| - តំណាងក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងវិស័យស្ថាបត្យកម្ម | សមាជិក |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃរាជរដ្ឋាភិបាល | សមាជិក |
| - តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| - តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| - អគ្គលេខាធិការ **គ.ស.ក.** | សមាជិកអចិន្ត្រៃយ៍ |

សមាសភាពក្រុមប្រឹក្សា **គ.ស.ក.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

**មាត្រា ៨.-**

ក្រុមប្រឹក្សា **គ.ស.ក.** មានសិទ្ធិទាក់ទងនិងអញ្ជើញតំណាងក្រសួង ស្ថាប័ននានាដែលពុំមានចែងក្នុងមាត្រា៧ខាងលើ សមាគម អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន អង្គការអន្តរជាតិ និងតំណាងប្រទេសនានាតាមការចាំបាច់ ដើម្បីចូលរួមប្រជុំផ្តល់យោបល់ឬធ្វើជាអ្នកសង្កេតការណ៍។

**មាត្រា ៩.-**

ក្រុមប្រឹក្សា **គ.ស.ក.** មានភារកិច្ចដូចតទៅ៖

- អនុម័តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ស្ថាបត្យករ
- អនុម័តថវិកាប្រចាំឆ្នាំរបស់ **គ.ស.ក.**
- តាមដាននិងត្រួតពិនិត្យដំណើរការការងាររបស់ **គ.ស.ក.**
- ផ្តល់យោបល់ដល់អគ្គលេខាធិការដ្ឋានអំពីការងារចាំបាច់
- សម្របសម្រួលនិងដោះស្រាយរាល់វិវាទផ្សេងៗរបស់ **គ.ស.ក.**
- ផ្តល់យោបល់ក្នុងការចុះបញ្ជីស្ថាបត្យករ ការលើកទឹកចិត្ត និងការដាក់វិន័យ។

**មាត្រា ១០.-**

ក្រុមប្រឹក្សា គ.ស.ក. ត្រូវប្រជុំយ៉ាងតិចរៀងរាល់១(មួយ)ឆ្នាំម្តង។ ក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សា គ.ស.ក. អាចកោះប្រជុំជាវិសាមញ្ញបាន។

## ផ្នែកទី៣

## អគ្គលេខាធិការដ្ឋាន

**មាត្រា ១១.-**

គ.ស.ក. ត្រូវមានអគ្គលេខាធិការដ្ឋានមួយដែលមានតួនាទីជាអង្គភាពប្រតិបត្តិនិងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ស្ថាបត្យករដែលអនុម័តដោយក្រុមប្រឹក្សា គ.ស.ក.
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការ គ.ស.ក.
- ធានានិរន្តរភាពការងាររបស់អគ្គលេខាធិការដ្ឋាន
- ផ្សព្វផ្សាយអនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងនឹងវិស័យស្ថាបត្យកម្មគ្រប់ជំនាញ និងចូលរួមរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងវិស័យស្ថាបត្យកម្មតាមការអញ្ជើញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ជួយការពារកម្មសិទ្ធិបញ្ញារបស់ស្ថាបត្យករចុះបញ្ជី
- ពង្រឹងសមត្ថភាពក្នុងការចូលរួមប្រកួតប្រជែងដោយយុត្តិធម៌និងស្មើភាពគ្នារវាងស្ថាបត្យករចុះបញ្ជីកម្ពុជានិងស្ថាបត្យករបរទេស
- ធ្វើសហប្រតិបត្តិការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា គ្រឹះស្ថានឧត្តមសិក្សា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់កម្មវិធីសិក្សាវគ្គបំប៉នជំនាញនិងការអប់រំឧត្តមសិក្សា
- លើកស្ទួយការបណ្តុះបណ្តាលបន្តដល់ស្ថាបត្យករកម្ពុជា ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈស្ថាបត្យកម្មឲ្យមានការទទួលស្គាល់ក្នុងក្របខ័ណ្ឌអាស៊ាននិងអន្តរជាតិ តាមគោលការណ៍នៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកក្នុងអាស៊ាន
- ពិនិត្យតាមដានការប្រកបវិជ្ជាជីវៈស្ថាបត្យកម្មរបស់ស្ថាបត្យករចុះបញ្ជីស្ថាបត្យករ គ.ស.ក. និងស្ថាបត្យករបរទេស
- ចុះបញ្ជីកំណត់គុណវុឌ្ឍិអាជីពវិជ្ជាជីវៈស្ថាបត្យកម្មរបស់រូបវន្តបុគ្គលឲ្យទៅជាស្ថាបត្យករ គ.ស.ក. និងធានានិរន្តរភាពនៃការចុះបញ្ជីស្ថាបត្យករនៅព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- ជ្រើសរើសនិងវាយតម្លៃលើបេក្ខភាពស្ថាបត្យករ **គ.ស.ក.** ដើម្បីឲ្យទៅជាស្ថាបត្យករអាស៊ាន
- រៀបចំគុណវុឌ្ឍិជំនាញវិជ្ជាជីវៈនិងក្រមសីលធម៌របស់ស្ថាបត្យករចុះបញ្ជីនិងស្ថាបត្យករ **គ.ស.ក.** ដោយសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ
- ធ្វើការត្រួតពិនិត្យលើការអនុវត្តការងាររបស់ស្ថាបត្យករចុះបញ្ជីនិងស្ថាបត្យករ **គ.ស.ក.** ក្នុងករណីមានទំនាស់ក្នុងការបំពេញវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **គ.ស.ក.** ក្នុងកិច្ចប្រជុំប្រចាំឆ្នាំនិងក្រុមប្រឹក្សា **គ.ស.ក.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនដោយក្រុមប្រឹក្សា **គ.ស.ក.**។

**មាត្រា ១២.-**

អគ្គលេខាធិការដ្ឋាន **គ.ស.ក.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់។ អគ្គលេខាធិការមានឋានៈទាបបំផុតស្មើរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមានឋានៈទាបបំផុតស្មើអនុរដ្ឋលេខាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ១៣.-**

អគ្គលេខាធិការនិងអគ្គលេខាធិការរង **គ.ស.ក.** ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយមហាសន្និបាត **គ.ស.ក.** សម្រាប់អាណត្តិ៥(ប្រាំ)ឆ្នាំ។

ស្ថាបត្យករមានសញ្ជាតិខ្មែរដែលអាចឈរឈ្មោះឲ្យមហាសន្និបាត **គ.ស.ក.** បោះឆ្នោតជាអគ្គលេខាធិការឬអគ្គលេខាធិការរងបាន ត្រូវមានឈ្មោះក្នុងបញ្ជីស្ថាបត្យករ **គ.ស.ក.** យ៉ាងតិច ៥(ប្រាំ)ឆ្នាំ ហើយមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយឡើយ។

**មាត្រា ១៤.-**

ក្នុងករណីដែលអគ្គលេខាធិការឬអគ្គលេខាធិការរងណាម្នាក់ទទួលមរណភាពឬលាឈប់ពីមុខងារក្នុងអាណត្តិរបស់ខ្លួននោះ **គ.ស.ក.** ត្រូវជ្រើសរើសអ្នកជំនួសដើម្បីបន្តបញ្ចប់អាណត្តិស្របតាមបទបញ្ជាផ្ទៃក្នុង។

**មាត្រា ១៥.-**

គ.ស.ក.មានរូបសញ្ញានិងត្រាដោយឡែករបស់ខ្លួន។

## ផ្នែកទី៤

## ក្រុមប្រឹក្សាគណៈស្ថាបត្យកររាជធានី ខេត្ត

**មាត្រា ១៦.-**

គ.ស.ក. អាចបង្កើតក្រុមប្រឹក្សាគណៈស្ថាបត្យកររាជធានី ខេត្តបាន ក្នុងករណីមានសមាជិកជាស្ថាបត្យករចាប់ពី២០(ម្ភៃ)រូបឡើងទៅ ដែលក្នុងនោះត្រូវមានស្ថាបត្យករ គ.ស.ក. យ៉ាងតិច៥(ប្រាំ)រូប។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគណៈស្ថាបត្យកររាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា គ.ស.ក.។

## ផ្នែកទី៥
## មហាសន្និបាត

**មាត្រា ១៧.-**

មហាសន្និបាតប្រចាំឆ្នាំរបស់គ.ស.ក. ត្រូវប្រព្រឹត្តទៅតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាគ.ស.ក.។

មហាសន្និបាត គ.ស.ក. ប្រព្រឹត្តទៅ៥(ប្រាំ)ឆ្នាំម្តង ដើម្បីរៀបចំការបោះឆ្នោតជ្រើសរើសអគ្គលេខាធិការនិងអគ្គលេខាធិការរង។

មហាសន្និបាតវិសាមញ្ញអាចប្រព្រឹត្តទៅបានតាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សា គ.ស.ក.ឬតាមការស្នើសុំពីស្ថាបត្យករ គ.ស.ក. យ៉ាងតិចចំនួន៣០(សាមសិប)ភាគរយ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ មុនថ្ងៃប្រជុំដោយមានភ្ជាប់របៀបវារៈមកជាមួយផង។

**មាត្រា ១៨.-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មហាសន្និបាត គ.ស.ក. ដូចមានចែងក្នុងមាត្រា១៧ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង គ.ស.ក.។

## ជំពូកទី៣
## ការប្រកបវិជ្ជាជីវៈស្ថាបត្យកម្ម

**មាត្រា ១៩.-**

ស្ថាបត្យករដែលអាចក្លាយទៅជាស្ថាបត្យករ គ.ស.ក. បានត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានចុះឈ្មោះក្នុងបញ្ជី គ.ស.ក.
- គ្មានការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈនេះដោយតុលាការ
- បំពេញលក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា គ.ស.ក.។

**មាត្រា ២០.-**

ស្ថាបត្យករដែលបានបំពេញគ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា១៩ខាងលើ ត្រូវទទួលបានវិញ្ញាបនបត្រស្ថាបត្យករ គ.ស.ក.ដែលចេញដោយ គ.ស.ក.។

**មាត្រា ២១.-**

ការប្រកបវិជ្ជាជីវៈស្ថាបត្យកម្ម ត្រូវគោរពតាមក្រមសីលធម៌ស្ថាបត្យករដែលអនុម័តដោយក្រុមប្រឹក្សា គ.ស.ក.។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ២២.-**

ស្ថាបត្យករបរទេសដែលមានបំណងប្រកបវិជ្ជាជីវៈស្ថាបត្យកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** និងត្រូវគោរពតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២៣.-**

ស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេសដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** នៅព្រះរាជាណាចក្រកម្ពុជាត្រូវបង់ភាគទានប្រចាំឆ្នាំជូន **គ.ស.ក.**។

ភាគទានដែលត្រូវបង់ជូន **គ.ស.ក.** ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា **គ.ស.ក.**។

**មាត្រា ២៤.-**

ស្ថាបត្យករចុះបញ្ជីនិងស្ថាបត្យករ **គ.ស.ក.** អាចសុំព្យួរឬសុំលាឈប់ពីសមាជិក **គ.ស.ក.** បានតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា **គ.ស.ក.**។

## ជំពូកទី៤
## គោរមងារ

**មាត្រា ២៥.-**

**គ.ស.ក.** អាចថ្វាយឬជូនគោរមងារជាមហាវរស្ថាបត្យករជាតិឬវរស្ថាបត្យករជាតិចំពោះឥស្សរជនជាន់ខ្ពស់ដែលមានគុណូបការៈក្នុងការដឹកនាំនិងស្ថាបនាជាតិ។

**មាត្រា ២៦.-**

**គ.ស.ក.** អាចផ្ដល់គោរមងារជាស្ថាបត្យករជាតិជូនចំពោះស្ថាបត្យករ **គ.ស.ក.** ដែលបានប្រកបវិជ្ជាជីវៈស្ថាបត្យកម្មរយៈពេល១៥(ដប់ប្រាំ)ឆ្នាំឡើងទៅ។

**គ.ស.ក.** អាចផ្ដល់គោរមងារជាស្ថាបត្យករកិត្តិយសជូនចំពោះឥស្សរជនឬបុគ្គលទាំងឡាយណាដែលបានឧបត្ថម្ភគាំទ្រផ្នែកថវិកាឬបច្ចេកទេសចំពោះ **គ.ស.ក.** តាមការកំណត់របស់ក្រុមប្រឹក្សា **គ.ស.ក.**។

**មាត្រា ២៧.-**

គោរមងារជាស្ថាបត្យករជាតិអាចត្រូវដកហូតវិញបាន ប្រសិនបើស្ថាបត្យកររូបនោះបានប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ស្ថាបត្យករ។

## ជំពូកទី៥
## ក្រុមប្រឹក្សាវិន័យ

**មាត្រា ២៨.-**

ក្រុមប្រឹក្សាវិន័យមានសមាសភាពចំនួន៥(ប្រាំ)រូប ដែលត្រូវតែងតាំងឡើងដោយប្រធានក្រុមប្រឹក្សា គ.ស.ក.ក្នុងចំណោមសមាជិកក្រុមប្រឹក្សា **គ.ស.ក.** និងសមាជិកនៃអគ្គលេខាធិការ **គ.ស.ក.**។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការសម្រេចដាក់វិន័យត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង គ.ស.ក.។

**មាត្រា ២៩.-**

ក្រុមប្រឹក្សាវិន័យមានតួនាទី ដូចតទៅ៖

- ទទួលបណ្តឹងតវ៉ាផ្សេងៗពាក់ព័ន្ធនឹងស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.**
- ដោះស្រាយវិវាទទាក់ទងនឹងវិជ្ជាជីវៈរបស់ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.**
- ដាក់ទណ្ឌកម្មខាងវិន័យដល់ស្ថាបត្យករណាដែលប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.**។

**មាត្រា ៣០.-**

ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចដាក់ទណ្ឌកម្មរបស់ក្រុមប្រឹក្សាវិន័យ មានសិទ្ធិប្តឹងតវ៉ាទៅប្រធានក្រុមប្រឹក្សា **គ.ស.ក.**។ ប្រធានក្រុមប្រឹក្សា **គ.ស.ក.** ត្រូវចាត់តាំងសមាជិកចំនួន៧(ប្រាំពីរ)រូបផ្សេងទៀតក្រៅពីសមាសភាពក្រុមប្រឹក្សាវិន័យ ដើម្បីពិនិត្យនិងសម្រេចលើបណ្តឹងតវ៉ានោះ។ សេចក្តីសម្រេចចុងក្រោយជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

បែបបទ នីតិវិធីនៃការតវ៉ា និងរយៈពេលនៃការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង **គ.ស.ក.**។

## ជំពូកទី៦
## ទណ្ឌកម្មខាងវិន័យ

**មាត្រា ៣១.-**

ទណ្ឌកម្មខាងវិន័យរួមមាន៖

- ការស្តីបន្ទោស
- ការព្រមាន
- ការព្យួរសិទ្ធិមួយរយៈពេល ដែលមិនអាចលើសពី២(ពីរ)ឆ្នាំ
- ការលុបឈ្មោះចេញពីបញ្ជី **គ.ស.ក.** ឬដកហូតគោរមងារស្ថាបត្យករជាតិ។

ការទទួលទណ្ឌកម្មខាងវិន័យ មិននាំឲ្យបុគ្គលនោះរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និងព្រហ្មទណ្ឌឡើយ។

## ជំពូកទី៧
## ប្រភពធនធាន

**មាត្រា ៣២.-**

ប្រភពធនធានរបស់ **គ.ស.ក.** សម្រាប់បំពេញការងាររបស់ខ្លួនបានមកពី៖

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- ភាគទានដែលបានពីសមាជិក គ.ស.ក.
- អំណោយនិងវិភាគទានពីដៃគូអភិវឌ្ឍ សហគមអន្តរជាតិ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ចំណូលបានពីសកម្មភាពនានារបស់ គ.ស.ក.
- ជំនួយឥតសំណងផ្សេងៗ។

គ.ស.ក. មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេសនិងសម្ភារៈផ្សេងៗទៀតពីប្រភពក្នុងនិងក្រៅប្រទេស សម្រាប់បម្រើការក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន។

## ជំពូកទី៨

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៣.-**

ក្នុងអាណត្តិដំបូង អគ្គលេខាធិការនិងអគ្គលេខាធិការរងនៃ គ.ស.ក. ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលតាមសំណើរបស់ប្រធានក្រុមប្រឹក្សា គ.ស.ក.។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា ៣៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៥.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៨. ១១១៧. ១១៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ [illegible] ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០១២
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**